**Program:** People Story Before Bed

**Topic:** Elon Musk (**ម្ចាស់ក្រុមហ៊ុន Tesla និង SpaceX**)

**Categories:** Successful People

**Publish Date:**

**Content by:** Prey Reung




---

**Hook:**

## សូមស្វាគមន៍មកកាន់ CamID Podcast

បុរសម្នាក់ដែលអ្នកតាមបណ្ដាញសង្គមអ៊ីនធឺណេតរាប់លាននាក់ អោយរហ័ស្សនាមថាជាបុរសដែលមានគំនិតសម្បូរបែប ក្នុងការបង្កើតអ្វីដែលថ្មីៗជាពិសេសគឺក្រុមហ៊ុនថ្មីៗ ហើយធ្លាប់ឈរឈ្មោះជាមហាសេដ្ឋីលំដាប់លេខ១លើពិភពលោក បុរសនោះមានឈ្មោះថា Elon Musk។

ជាការពិតណាស់ បើយើងនឹកទៅដល់ឡានសេរីទំនើបម៉ាក Tesla និងក្រុមហ៊ុនយក្សយានអាវកាស SpaceX យើងប្រកដជាដឹងហើយថាលោក Elon Musk គឺជាអ្នកស្ថាបនិកនៃក្រុមហ៊ុនទាំងនោះ ក៏ប៉ុន្តែបើអ្នកទាំងអស់គ្នា ងាកមកសិក្សាអោយស៊ីជម្រៅ ទៅលើជីវប្រវត្តិរបស់គាត់ យើងប្រាកដជាបានសិក្សា និងស្វែងយល់ពីជីវិតជោគជ័យ និងបរាជ័យរបស់គាត់។

លើសពីនេះទៅទៀត យើងក៏អាចដឹងដែរ ថា ភាពអស្ចារ្យដែលនៅពីក្រោយខ្នងក្រុមហ៊ុនរបស់គាត់ គឺមានវិសាលភាពប៉ុនណា។ ដូច្នេះកុំអោយខាតពេលយូរ ថ្ងៃនេះព្រៃរឿងនឹងនាំយកខ្សែជីវិតរបស់លោក Elon Muskមកបកស្រាយ។

**Intro:**

មុននឹងចូលដល់ជីវិប្រវត្តិស៊ីជម្រៅ ព្រៃរឿងសូមបញ្ជាក់ពីផលសម្រេចត្រួសៗរបស់គាត់ជាមុនសិន ដើម្បីឲ្យប្រិយមិត្តមួយចំនួនដែលពុំទាន់ស្គាល់គាត់បានជ្រាបថាគាត់ជានរណា។

Elon Musk គឺជាសហក្រិន និងអ្នកជំនួញសញ្ជាតិអាហ្វ្រិកខាងត្បូង និងអាមេរិកមួយរូប រស់នៅសហរដ្ឋអាមេរិក។ លោកគឺជាអ្នករកឃើញក្រុមហ៊ុន X.com នៅឆ្នាំ១៩៩៩ ប៉ុន្តែឥឡូវក្រុមហ៊ុននេះ បានវិវត្តខ្លួនទៅជាក្រុមហ៊ុន Paypal ហើយ។

នៅឆ្នាំ២០០២ Elon បានរកឃើញក្រុមហ៊ុនយានអាវកាស SpaceX បន្ទាប់មករំលងគ្នាតែមួយឆ្នាំប៉ុណ្ណោះ Elon បានបង្កើតក្រុមហ៊ុនថ្មីមួយទៀត គឺក្រុមហ៊ុនTesla។

ក្រោយមកនៅឆ្នាំ២០១២ Elon បានបង្ហោះរ៉ូកែត ទៅកាន់ទីអាវកាសជាលើកដំបូង ព្រមគ្នាជាមួយនឹងយានពាណិជ្ជកម្មរបស់ខ្លួនជាលើកដំបូង ដែលកាលនោះធ្វើអោយឈ្មោះរបស់ Elon Musk ត្រូវបានគេស្គាល់ជាច្រើនទូទាំងពិភពលោក។

កេរ្តិ៍ឈ្មោះរបស់លោកគ្រានោះ បានធ្វើអោយលោក ក្លាយទៅជាទីប្រឹក្សារបស់អតីតប្រធានាធបតី Donald Trump ក្នុងការងាររដ្ឋបាលថែមទៀតផង។ បន្ទាប់មក ក្នុងខែមករា ឆ្នាំ២០២១នេះ ឈ្មោះរបស់ Elon Musk បានវ៉ាដាច់មហាសេដ្ឋីពិភពលោកគឺលោក Jezz Bezos ក្នុងការឈរឈ្មោះ ជាសេដ្ឋីលំដាប់កំពូលដែលមានទ្រព្យសម្បត្តិច្រើនជាងគេនៅលើពិភពលោក។

ចង់ដឹងថា មូលហេតុអ្វីទើបលោកមានថ្ងៃនេះ? តោះមកស្តាប់ព្រៃរឿងបកស្រាយទាំងអស់គ្នា!

**Body**:

Elon មានឈ្មោះពេញថា Elon Reeve Musk កើតនៅថ្ងៃទី២៨ ខែមិថុនា ឆ្នាំ១៩៧១ នៅក្នុងទីក្រុង Pretoria នៃប្រទេសអាហ្វ្រិកខាងត្បូង។ គ្រួសាររបស់លោកជាត្រកូលអភិជនមួយ ពោលគឺម្តាយរបស់លោកឈ្មោះ Mayne Musk គឺជាអតីតជាម៉ាម៉ូឌែលសញ្ញាតិកាណាដាម្នាក់ រីឯឪពុករបស់លោកឈ្មោះ Errol Musk គឺជាអ្នកវិស្វករ ដែលមានទ្រព្យសម្បត្តិស្តុកស្តមមួយរូប នៅអាហ្វ្រិកខាងត្បូង។

យ៉ាងណាក្តី Elon បានចំណាយពេលកុមារភាពជាមួយបងប្រុសរបស់គេឈ្មោះ Kimbal និងបងស្រីរបស់គាត់គឺ Tosca ព្រោះម្តាយឪពុករបស់គាត់បានបែកបាក់គ្នាតាំងពី Elon អាយុ១០ឆ្នាំមកម្លេះ។

Elon គឺជាក្មេងម្នាក់ ដែលខុសពីក្មេងដទៃ។ កាលពីនៅក្មេង Elon គឺជាក្មេងម្នាក់ ដែលមានគំនិតវើរវាយ និងឈ្លក់វង្វេងជាមួយគំនិតបង្កើតអ្វីថ្មីៗ រហូតទាល់តែឪពុករបស់គាត់ យកគាត់ទៅពេទ្យដើម្បីពិនិត្យបញ្ហាត្រចៀកថែមទៀតផង។ Elon គឺជាក្មេងដែលស្រគត់ស្រគំ មិនសូវចេះនិយាយស្តីនោះទេ Elon តែងតែចូលចិត្តអានសៀវភៅ។

ហើយអ្វីដែលគួរអោយចាប់អារម្មណ៍នោះ គឺស្របពេលដែលឪពុកម្តាយរបស់ Elon កំពុងតែមានជម្លោះ គាត់បានបង្រៀនខ្លួនគាត់ អោយចេះសរសេរកូដប្រូក្រាមក្នុងកំព្យូទ័រ។ ក្រោយមកនៅពេលគាត់មានអាយុ១២ឆ្នាំគាត់បានលក់ Software Game ជាលើកដំបូងរបស់គាត់ដែលហៅថា Blastar។

នៅពេល Elon អាយុ១៧ឆ្នាំ ពេលគឺនៅឆ្នាំ១៩៨៩ Elon បានផ្លាស់ប្តូរទីលំនៅទៅរស់នៅប្រទេស Canada ដើម្បីបន្តការសិក្សានៅឯសកលវិទ្យាល័យ Queen University ណាមួយក៏ដើម្បីគេចខ្លួនពីការចូលបម្រើកងទ័ពនៅឯអាហ្វ្រិកខាងត្បូងដែរ។ Elon គិតថាវាក៏ងាយស្រួលដែរ ដែលរូបគេអាចចូលជាសញ្ជាតិជាអាមេរិកនៅពេលនោះ។

បន្ទាប់ពីរៀននៅសកលវិទ្យាល័យ Queen បាន៣ឆ្នាំ នៅឆ្នាំ១៩៩២ Elon បានចាកចេញពីសកលវិទ្យាល័យនោះ រួចក៏បន្តសិក្សាជំនាញ Business និងរូបវិទ្យានៅឯសកលវិទ្យា Pennsylvania នៃប្រទេសសហរដ្ឋអាមេរិកវិញម្តង។

ក្រោយពីបានបញ្ចប់ការសិក្សានៅ Pennsylvania រួច Elon ក៏បានបន្តការសិក្សាយក ថ្នាក់បណ្ឌិត ខាងផ្នែកថាមពលរូបវិទ្យា នៅសកលវិទ្យាល័យ Stanford នៃរដ្ឋ California ផងដែរ។

ការផ្លាស់ប្តូររបស់គាត់គឺជាពេលដ៏ល្អបំផុតមួយ ដោយគ្រានោះ គឺជាពេលដែលប្រព័ន្ធ Internet បានផ្ទុះឡើងយ៉ាងខ្លាំង។ ដោយសម្លឹងមើលឃើញពីផលប្រយោជន៍របស់វា ក្រោយពីរៀននៅសកលវិទ្យា Stanford បានតែពីរថ្ងៃ Elon ក៏បានសម្រេចចិត្តបោះបង់ការសិក្សាចោល រួចក៏ចូលខ្លួនបង្កើតក្រុមហ៊ុនមួយឈ្មោះថា Zip2 Corporation នៅឆ្នាំ១៩៩៥ ជាមួយបងប្រុសរបស់គាត់គឺ

គួរបញ្ជាក់ផងដែរថា ក្រុមហ៊ុននេះ គឺជាក្រុមហ៊ុនមួយដែលផ្តល់សេវាកម្មមាតិកា អោយវេបផ្សាយល្បីៗមួយចំនួន ដូចជា The New York Time និង Chicago Tribune ជាដើម។

ក្រោយមកនៅឆ្នាំ១៩៩៩ ក្រុមហ៊ុន Computer មួយក៏បានទិញក្រុមហ៊ុន Zip2 នេះក្នុងតម្លៃ ៣០៧ លានដុល្លារ និង ៣៤លានដុល្លារក្នុងស្តុក។

ក្រោយពីគាត់បានបានប្រាក់ពីការលក់ក្រុមហ៊ុន Zip2 របស់គាត់ ពេលគឺនៅឆ្នាំ១៩៩៩ Elon និង Kimbal បានយកលុយទាំងនោះ ទៅបង្កើតក្រុមហ៊ុនមួយទៀតមានឈ្មោះថា X.com

ក្នុងគោលបំណងបម្រើសេវាកម្មហិរញ្ញវត្ថុ និងសេវាកម្មបង់ប្រាក់តាមប្រព័ន្ធអ៊ីនធឺណែត ដែលក្រោយមកបានផ្លូវឈ្មោះទៅជា Paypal ដូចដែលយើងស្គាល់ក្នុងពេលបច្ចុប្បន្ននេះឯង។

ដោយឡែកនៅឆ្នាំ២០០២ Elon បានសន្សំប្រាក់ពី Paypal របស់គាត់ជាលើកដំបូងរហូតដល់១ពាន់លានឯនោះ ក្រោយពីក្រុមហ៊ុន eBay ទិញក្រុមហ៊ុនរបស់គាត់ក្នុងតម្លៃ ១.៥ពាន់លាន។

ក្រុមហ៊ុនទាំងពីរនេះ មិនទាន់គ្រប់គ្រាន់សម្រាប់ Elon នោះទេ នៅឆ្នាំ ២០០២ ដដែរ Elon បានរកឃើញក្រុមហ៊ុនដ៏ធំថ្មីមួយទៀតគឺ SpaceX។

Elon បង្កើតក្រុមហ៊ុននេះឡើងដើម្បីផ្តោតទៅលើបបច្ចេកវិទ្យា ក្នុងការរុករកនៅលើភពអាវកាស និងក្នុងគោលបំណងសាងសង់យានអាវកាស ដើម្បីបញ្ជូនមនុស្សលោក ធ្វើដំណើរទៅក្រៅភពនៅថ្ងៃអនាគត។

រំលងបាន៦ឆ្នាំ SpaceX ត្រូវបានគេស្គាល់ជាក្រុមអាវកាសដែលល្អមួយ នៅក្នុងឆ្នាំ២០០៨ មិនតែប៉ុណ្ណោះ ទីភ្នាក់ងារអវកាសសហរដ្ឋអាមេរិច NASA ក៏បានសម្រេចអោយរង្វាន់ ដោយអោយ SpaceX ចុះកុងត្រាជាមួយគ្នា ក្នុងការដឹកទំនិញទៅកាន់ស្ថានីយអន្តរជាតិអាវកាស និងដឹកអាកាសចរនៅថ្ងៃមុខ ហើយថែមទាំងដើរតួ ជាអ្នកជំរុញអោយ NASA សម្រេចបេសកម្មនានាទៀតផង។

សម្មិទ្ធផលជាច្រើនកាន់ តែកើតមានជាបន្តបន្ទាប់ នៅពេលដែលក្រុមហ៊ុន SpaceX មានតួនាទីសំខាន់នៅក្នុងក្រុមហ៊ុន NASA។

នៅថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១២ Elon Musk និងក្រុមហ៊ុន SpaceX របស់គាត់ បានបំបែកកំណត់ត្រាប្រវត្តិសាស្ត្រ ជាលើកដំបូងក្នុង NASA ដោយបានបញ្ជូនរ៉ូកែត Falcon9 ជាមួយទំនិញ ជាង ៤៥០ គម ទៅអោយអាកាសយានិក ដែលនៅលើយានអាវកាសអន្តរជាតិ អ្វីដែលធ្វើអោយមនុស្សក្នុងពិភពលោកយើងភ្ញាក់ផ្អើលនោះ គឺយានអាវកាស Falcon9 នេះ មិនមានមនុស្សបើកនោះទេ គឺវាបើកដោយស្វ័យប្រវត្តិ។

នៅខែធ្នូ ឆ្នាំ២០១៣ រ៉ូកែត Falcon9 បានធ្វើការជោគជ័យម្តងទៀត ទៅលើការបញ្ជូនផ្កាយរណបទៅអាវកាស ដើម្បីអោយវាជាប់ និងដើរលើគន្លងជុំវិញភពផែនដី។ នេះគឺជាការជោគជ័យដ៏ធំមួយ ក្នុងការដាក់ផ្កាយរណបទៅតាមទីតាំង ដែលពួកគេចង់ដាក់។

យ៉ាងណាក៏ដោយការបរាជ័យ ក៏កើតមានឡើងនៅឆ្នាំ២០១៧ គឺនៅពេលដែល SpaceX កំពុងតែធ្វើតេស្តទៅលើម៉ាស៊ីនថ្មី ស្រាប់តែមានការផ្ទុះ សំណាងល្អ ដែលមិនមានអ្នកណារងរបួសនៅក្នុងហេតុការណ៏នេះ។

នៅខែមីនា ឆ្នាំ២០១៨ SpaceX បានទទួលលិខិតអនុញ្ញាតមួយពីរដ្ឋាភិបាលរបស់អាមេរិក ក្នុងការបញ្ជូនផ្កាយរណប ទៅលើអាវកាស ដែលស្ថិតនៅចំនុចគន្លងទាប ក្នុងគោលបំណងផ្តល់សេវាកម្ម Internet ទៅកាន់តំបន់ដាច់ស្រយាលមួយចំនួន ជុំវិញពិភពលោក ដែលគម្រោងមួយនេះមានឈ្មោះថា Starlink។

មិនយូរប៉ុន្មាន នៅខែឧសភា ឆ្នាំ២០១៩ ក្រុមហ៊ុន SpaceX ក៏បានបង្ហោះផ្កាយរណបចំនួន ៦០ ទៅកាន់អាវកាស និងបន្តបង្ហោះ ៦០បន្ថែមទៀត នៅខែវិច្ឆិកាផងដែរ។

ស្របពេលដែល Elon កំពុងតែកាន់ក្រុមហ៊ុន SpaceX Elon ក៏មានក្រុមហ៊ុនយានយន្តដ៏ធំមួយទៀត នៅសហរដ្ឋអាមេរិកដែរ គឺក្រុមហ៊ុន Tesla ដែល Elon គឺជាម្ចាស់ជំនួញផង ជាអ្នកត្រួតពិនិត្យ និងច្នៃប្រឌិតផលិតផលផង។ ក្រុមហ៊ុនTesla ត្រូវបានបង្កើតឡើងក្នុងឆ្នាំ ២០០៣ ក្នុងគោលបំណងផលិតរថយន្តអគ្គិសនី និងផលិតផលផ្សេងៗដូចជាថ្ម និងផ្ទាំងសូឡាជាដើម។

អស់រយះពេល១៨ ឆ្នាំហើយ ដែលក្រុមហ៊ុន Tesla បានបង្កើតមក។

Teslaបានផលិតរថយន្តសេរីទំនើបជាច្រើនម៉ូឌែល ដែលមាន Tesla Roadster គឺជាម៉ូឌែលដំបូងគេ បង្កើតនៅឆ្នាំ2008 ហើយម៉ូឌែលជំនាន់ក្រោយៗទៀត គឺមានដូចជា Model S, Model X, Model 3 និង Model Y។

ចំណែកឯមូលហេតុ ដែលធ្វើអោយមនុស្សជាច្រើនជុំវិញពិភពលោក រួមមានទាំងប្រជាជនខ្មែរគាំទ្ររថយន្តរបស់ Tesla នោះ គឺដោយសារតែបច្ចេកវិទ្យាបើកដោយស្វ័យប្រវត្តិ និងបច្ចេកវិទ្យាជិះឡានសាកថ្ម ដោយមិនចាំបាច់ប្រើសាំង ម៉្យាងវិញទៀត វាក៏ជួយថែរក្សាបរិស្ថានមួយផ្នែកធំផងដែរ។

តែទោះជាយ៉ាងណាក៏ដោយ គ្រប់មនុស្ស មិនមែនចេះតែជោគជ័យរហូតនោះទេ។

រឿងរ៉ាវដែលធ្វើអោយលោកអាម៉ាសមុខ នៅក្នុងក្រុមហ៊ុន Tesla នោះគឺកាលពីខែធ្នូ ឆ្នាំ២០១៧ លោកបានប្រកាសថា Tesla នឹងផលិតរថយន្ត Model3 អោយបានចំនួន ៥០០០គ្រឿង ក្នុងមួយអាទិត្យ ក្រោយមក Elon ក៏លើកទៅខែធ្នូ ឆ្នាំ២០១៨ ហើយក្រោយមកទៀត ក៏លើកទៅខែមិថុនាទៅវិញ។

ការពន្យាពេលបែបនេះ មិនបានធ្វើអោយអ្នកជំនាញភ្ញាក់ផ្អើលនោះទេ ព្រោះពួកគេដឹងថា មានបញ្ហាក្នុងការផលិតរួចមកហើយ អ្វីដែលសំខាន់នោះគឺថា តើអ្នកវិនិយោគលើម៉ូឌែលមួយនេះ មានការអត់ធ្មត់យូរប៉ុនណា។

កាលពីខែមករា ឆ្នាំ២០១៧ Elon ក៏បានដាក់ដំណើរការក្រុមហ៊ុនមួយទៀតដែរ គឺ The Boring Company។ ក្រុមហ៊ុននេះផ្តោតទៅលើការកាត់បន្ថយការស្ទះចរាចរណ៏ ដោយបង្កើតផ្លូវរូងក្រោមដី។ Elon ផ្តើមធ្វើតេស្តជីកដំបូងន្ទៅក្នុងបរិវេណក្រុមហ៊ុនSpaceXនៅLos Angelesមុនគេ។ ក្រោយមកនៅឆ្នាំ២០១៩ ក្រុមហ៊ុននេះបានទទួលប្រាក់ពីរដ្ឋ Las Vega ចំនួន ៤៨.៧លានដុល្លារ ក្នុងការសាងសង់ផ្លូវក្រោមដី ដើម្បីកាត់បន្ថយការកកស្ទះចរាចរណ៏នៅរដ្ឋ Las Vegas។

ក្រៅពីក្រុមហ៊ុនរបស់គាត់ Elon ក៏មានគំនិតក្នុងការបង្កើតគម្រោងផ្សេងៗដែរ គឺនៅឆ្នាំ២០១៣ Elon បានបញ្ចេញគំនិតមួយ ទាក់ទងទៅនឹងការធ្វើដំណើរ ដែលផ្តោតទៅលើរថភ្លើង Hyperloop ដែលមានល្បឿនលឿនជាងយន្តហោះ និងរថភ្លើងដទៃទៀត។ លោកក៏បានបញ្ជាក់ដែរ ថាវាត្រូវពេល១០ឆ្នាំ និងប្រាក់ចំនួន៦ពាន់លានឯនោះ ក្នុងការសាងសង់វា។

គំនិតមួយនេះទទួលបានសំនួររិះគន់ជាច្រើន តែយ៉ាងណាក៏មានសហាក្រិនជាច្រើនផ្សេងទៀតនៅតែគាំទ្រគំនិតមួយនេះដែរ។

ជាចុងក្រោយ Elon Musk គឺជាមនុស្សម្នាក់ ដែលមនុស្សជាច្រើនជុំវិញពិភពលោកស្ងើចសរសើរ ក៏ព្រោះតែស្នាដៃ និងគំនិតផ្លែកៗ និងភាពឆ្លាតវៃរបស់គាត់នោះឯង។ ហើយគំនិតមួយដែលមនុស្សគ្រប់គ្នាទន្ទឹងរង់ចាំមើលនោះ គឺការបញ្ជូនមនុស្សទៅរស់នៅភពអង្គារ។

មកទល់បច្ចុប្បន្ន បើក្រឡេកទៅមើលជីវិតផ្ទាល់ខ្លួនរបស់គាត់វិញគឺ Elon Musk គឺជាបុគ្គលជោគជ័យ ហើយក៏សេដ្ឋីល្បីល្បាញ លំដាប់ថ្នាក់ពិភពលោកមួយរូប ដែលមានទ្រព្យសម្បត្តិ និងលុយកាក់រាប់ពាន់យានដុល្លារ។

គាត់រស់នៅយ៉ាងស៊ីវិល័យ ជាមួយកូន៦នាក់របស់គាត់។ Elon បានរៀបការពីរលើក គឺប្រពន្ធទីមួយរបស់លោកឈ្មោះ Justin Wilson រៀបការនៅឆ្នាំ២០០០ មានកូន៦នាក់ ប៉ុន្តែកូនប្រុសដំបូងរបស់លោកបានស្លាប់ បន្ទាប់ពីកើតបានតែ ១០សប្តាហ៍ដោយជម្ងឺម្យ៉ាង។

លោកសល់កូន៥នាក់ជាមួយ Wilson។ ចំណែកឯប្រពន្ធទី២របស់គាត់ គឺGrimes រៀបការនៅឆ្នាំ២០១៨ និងមានកូន១នាក់។

ក្រៅពីហ្នឹង Elon ក៏មានអង្គការផ្ទាល់ខ្លួនមួយដែរ គឺឈ្មោះ Musk Foundation ដែលផ្តោតសំខាន់តែលើការរុករកអ្វីថ្មីៗ នៅក្រៅភពតែប៉ុណ្ណោះ។ ហើយនៅខែតុលារ ឆ្នាំ២០១៩ Elon បានឧបថម្ភទឹកប្រាក់ចំនួន ១លានដុល្លារ ទៅលើយុទ្ធនាការដាំដើមឈើផងដែរ ដោយកាលនោះ លោកបានផ្លូរឈ្មោះនៅក្នុង Instagram របស់លោកថា Treelon ដើម្បីបង្ហាញថាលោកជាមនុស្សដែលស្រលាញ់បរិស្ថាន។

**Ending**

តាមរយៈរឿងរ៉ាវរបស់គាត់ យើងអាចស្វែងយល់ពីចំណុចល្អជាច្រើន ដែលយើងអាចយកមកធ្វើការពិចារណាបាន។

ចំនុចដែលយើងគួរកត់សម្គាល់នោះ ការដែលរៀនយល់ពីចំណង់ចំណូលចិត្តរបស់ខ្លួនឯង រួចហើយអភិវឌ្ឍវា ដើម្បីឈានទៅរកការបង្កើតអ្វីដែលថ្មីសម្រាប់ខ្លួនឯង គ្រួសារ និងសង្គមជាតិ។

ហើយបើយើងចង់អោយវាមានសារៈប្រយោជន៍ ចំពោះពិភពលោក យើងត្រូវចេះស្វែងរកអ្វី ដែលពិភពលោកមិនទាន់មាន និងបង្កើតវាសម្រាប់អោយមនុស្សទូទាំងពិភពលោកអាចប្រើប្រាស់បាន។

Links and Resources

https://www.biography.com/

https://www.marketwatch.com/

https://venturebeat.com/